# ព្រះរាជក្រម

នស/រកម/០២០៧/០០៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រ កត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣ របស់អាស៊ានស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

/3 w

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើពិធីសារទី ៣ របស់
## អាស៊ានស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី ៣ របស់អាស៊ានស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក ដែលធ្វើនៅទីក្រុងហាណូយ ប្រទេសវៀតណាម នាថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៧០២.០៦៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
**ហត្ថលេខា**
**ស៊ុន ចាន់ថុល**

លេខៈ ៩២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

**ឃុន ជិនកេន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

# ពិធីសារអាស៊ាន

## ពិធីសារទី ៣

## ស្តីពី

## ប្រភេទ និងបរិមាណយានយន្តផ្លូវគោក

## TYPES AND QUANTITY OF ROAD VEHICLES

**នាយកដ្ឋានផែនការ - មិថុនា ២០០២**

PLANNING DEPARTMENT, JUNE 2002

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

៖....៤៥....សជណ.កបច

## សេចក្តីថ្លែងហេតុនៃ

## សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រម លើពិធីសារអាស៊ាន ស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក

### ក- លំនាំដើម

នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី ៥ របស់រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៤-១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានបានឯកភាពយល់ព្រម និងចុះហត្ថលេខា លើពិធីសារ និងកិច្ចព្រមព្រៀងចំនួន ៣ ដូចខាងក្រោម ៖

- ពិធីសារទី ៣ ៖ ស្តីពីការកំណត់ប្រភេទ និងបរិមាណយានយន្តដឹកជញ្ជូនផ្លូវគោក
- ពិធីសារទី ៤ ៖ ស្តីពីតម្រូវការបច្ចេកទេសរបស់យានយន្ត
- កិច្ចព្រមព្រៀងថ្នាក់រដ្ឋមន្ត្រីស្តីពីការអភិវឌ្ឍបណ្តាញផ្លូវអាស៊ានហាយវ៉េ

ពិធីសារទី ៣ គឺជាពិធីសារលំអិតផ្នែកបច្ចេកទេស សម្រាប់អនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្រួលក្នុងការដឹកជញ្ជូនទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានាខែ សីហា ឆ្នាំ ១៩៩៨ នៅទីក្រុងហាណូយ ប្រទេស វៀតណាម ដែលជាកិច្ចព្រមព្រៀងមួយនៅក្នុងចំណោមកិច្ចព្រមព្រៀង និងពិធីសារទាំង ២៧ របស់អាស៊ាន ហើយដែលសភាជាតិបានផ្តល់សច្ចាប័នទទួលស្គាល់រួចហើយកាលពីឆ្នាំ ២000 កន្លងទៅ បន្ទាប់ពីកម្ពុជាបានចូលជាសមាជិកអាស៊ាន។ កិច្ចព្រមព្រៀងនេះ តម្រូវឱ្យប្រទេសជាសមាជិកយល់ព្រម និងចុះហត្ថលេខាលើពិធីសារចំនួន៩ ដែលលំអិតខាងបច្ចេកទេសសម្រាប់អនុវត្តកិច្ចព្រមព្រៀង ៖

ពិធីសារទី១៖ការកំណត់ទុកជាមុននៃផ្លូវនិងមធ្យោបាយលើផ្លូវថ្នល់សម្រាប់សម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់

ពិធីសារទី ២ ៖ ការកំណត់ជាមុននៃប៉ុស្តិ៍ត្រួតពិនិត្យតាមព្រំដែន

ពិធីសារទី ៣ ៖ប្រភេទ និងបរិមាណនៃយានយន្តតាមផ្លូវគោក

ពិធីសារទី ៤ ៖ តម្រូវការខាងបច្ចេកទេសនៃយានយន្ត

ពិធីសារទី ៥ : ផែនការអាស៊ាននៃការធានារ៉ាប់រងក្នុងកាតព្វកិច្ចទទួលខុសត្រូវរបស់យានយន្ត

ពិធីសារទី ៦ : ព្រំដែនផ្លូវដែក និងស្ថានីយបំបែកផ្លូវដែកទាំងឡាយ

ពិធីសារទី ៧ : ប្រព័ន្ធគយសម្រាប់ការឆ្លងកាត់

ពិធីសារទី ៨ : វិធានការអនាម័យ និងភូតគាមអនាម័យ

ពិធីសារទី ៩ : ទំនិញគ្រោះថ្នាក់

មានពិធីសារចំនួន ៣ ដែលបានចុះហត្ថលេខារួចហើយដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន :

ពិធីសារទី ៣ : ប្រភេទ និងបរិមាណនៃយានយន្តតាមផ្លូវគោក ( ចុះហត្ថលេខានៅឆ្នាំ ១៩៩៩)

ពិធីសារទី ៤ : តម្រូវការខាងបច្ចេកទេសនៃយានយន្ត ( ចុះហត្ថលេខានៅឆ្នាំ ១៩៩៩)

ពិធីសារទី ៩ : ទំនិញគ្រោះថ្នាក់ ( ចុះហត្ថលេខាកាលពីឆ្នាំ ២០០២ និងកំពុងសុំសច្ចាប័នពីរដ្ឋសភាជាតិ)

មានពិធីសារចំនួន ០២ ទៀតបានចុះហត្ថលេខានៅចុងឆ្នាំ ២០០០ និងដើមឆ្នាំ ២០០១
ដោយក្រសួង ស្ថាប័នផ្សេងៗ :

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ពិធីសារទី ៥ : ផែនការអាស៊ាននៃការធានារ៉ាប់រងក្នុងកាតព្វកិច្ចទទួលខុសត្រូវរបស់យានយន្ត

(ពិធីសារនេះ បានផ្តល់សច្ចាប័នរួចហើយពីរដ្ឋសភាជាតិកាលពីឆ្នាំ ២០០២ កន្លងទៅ)

ក្រសួងកសិកម្ម និងក្រសួងសុខាភិបាល

- ពិធីសារទី ៨ : វិធានការអនាម័យ និងភូតគាមអនាម័យ

(ពិធីសារនេះ បានផ្តល់សច្ចាប័នរួចហើយពីរដ្ឋសភាជាតិកាលពីឆ្នាំ ២០០២ កន្លងទៅ)

មានពិធីសារ ៤ ទៀតដែលពុំទាន់បានចុះហត្ថលេខា :

-ពិធីសារទី១ : ការកំណត់ទុកជាមុននូវ និងមធ្យោបាយលើផ្លូវថ្នល់សម្រាប់សម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់ ។ បច្ចុប្បន្នពិធីសារនេះបានឈានចូលដល់ដំណាក់កាលឯកភាពគ្នា នឹងចុះហត្ថលេខានៅខែ វិច្ឆិកា ឆ្នាំ ២០០៥ ក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានលើកទី ១១ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ។

- ពិធីសារទី ៦ : ព្រំដែនផ្លូវដែក និងស្ថានិយបំបែកផ្លូវដែកទាំងឡាយ (ពិធីសារនេះនៅរង់ចាំចម្លើយជាចុងក្រោយពីប្រទេសសិង្ហបុរី និងអាចចុះហត្ថលេខាបាននៅឆ្នាំ ២០០៦ ខាងមុខ) រាជរដ្ឋាភិបាលបានផ្តល់សិទ្ធិ

ប្រទានរួចហើយជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចុះហត្ថលេខាកាលពីឆ្នាំ ២០០១ និង ២០០៤ កន្លងទៅ ។

- ពិធីសារ ២ : ការកំណត់ជាមុននៃប៉ុស្តិ៍តាមព្រំដែន
- ពិធីសារ ៧ : ប្រព័ន្ធគយសម្រាប់ការឆ្លងកាត់

ពិធីសារទាំង ២ នេះ ជាសមត្ថកិច្ចរបស់ស្ថាប័នគយ ដែលត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ប៉ុន្តែត្រូវជាប់គាំងដោយពិធីសារទី១ : (ការកំណត់ទុកជាមុននៃផ្លូវ និងមធ្យោបាយលើផ្លូវផ្តល់សម្រាប់សម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់) ដែលពុំទាន់អាចចុះហត្ថលេខាបាន ។

ពិធីសារទី ៣ មាន ៨ មាត្រា និងឧបសម្ព័ន្ធ ១ ដែលបានចុះហត្ថលេខានៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន ។

គោលបំណង នៃពិធីសារទី ៣ គឺដើម្បីកំណត់ប្រភេទ និង បរិមាណយានយន្ត សម្រាប់អនុវត្តក្នុងការសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់ កំណត់កាតព្វកិច្ច និងការរៀបចំស្ថាប័នរបស់ភាគីចុះកិច្ចសន្យា ឬប្រទេសជាសមាជិក និងការចូលរួមរបស់ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ ។

I- ខ្លឹមសារសង្ខេប និងចំណុចសំខាន់ៗ

-ពិធីសារបានកំណត់និយមន័យ ប្រភេទ និងវិសាលភាព នៃការអនុវត្តទៅលើគ្រប់យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវថ្នល់ និងប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់។ ភាគីទាំងឡាយយល់ព្រមថា ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់អាចអនុញ្ញាតឱ្យប្រើប្រាស់យានយន្តទៅតាមប្រភេទ និងបរិមាណដូចបានកំណត់ក្នុងពិធីសារ និងឧបសម្ព័ន្ធរបស់វា។ ជាជំហានដំបូងបរិមាណយានយន្តចំនួន៦០គ្រឿងសម្រាប់ភាគីនីមួយៗ ត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ ហើយបរិមាណនេះត្រូវលើកយកមកពិភាក្សា កែប្រែជាបន្តបន្ទាប់ដោយភាគីទាំងអស់

-ភាគីទាំងអស់យល់ព្រមឱ្យយានយន្តដឹកជញ្ជូនឆ្លងកាត់ ចេញ-ចូល និងចល័តដោយសេរី នៅលើផ្លូវដែលបានកំណត់ក្នុងពិធីសារទី១។ យានយន្តដឹកជញ្ជូនឆ្លងកាត់របស់ភាគីនីមួយៗ ដែលធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ទឹកដីភាគីដទៃត្រូវគោរព និងអនុវត្តទៅតាមបទប្បញ្ញត្តិទាំងឡាយ នៃការដឹកជញ្ជូនតាមផ្លូវថ្នល់ នៃភាគីនោះ ។ យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវថ្នល់ទាំងនោះ ត្រូវបំពេញទៅតាមតម្រូវការខាងបច្ចេកទេសត្រឹមត្រូវដូចកំណត់ក្នុងពិធីសារទី ៣ ទើបអាចធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់បាន

-កិច្ចប្រជុំមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់ គឺជាអ្នកទទួលខុសត្រូវសម្របសម្រួល ត្រួតពិនិត្យ និងធ្វើរបាយការណ៍ទៀងទាត់អំពីភាពជឿនលឿនក្នុងការអនុវត្តពិធីសារនេះ ជូនក្រុមប្រឹក្សាសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ថ្នាក់តំបន់របស់អាស៊ាន ដោយមានការជួយទ្រទ្រង់ខាងបច្ចេកទេស និងតាមរយៈលេខាធិការដ្ឋានអាស៊ាន

-ពិធីសារនេះត្រូវបានគេចុះហត្ថលេខា និងតម្កល់ទុកនៅលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកចែកផ្សព្វផ្សាយឱ្យបានរហ័សទៅគ្រប់ភាគី

- ពិធីសារនេះ និងឧបសម្ព័ន្ធរបស់វា គឺជាផ្នែកបញ្ចូលគ្នា ជាមួយកិច្ចព្រមព្រៀង

- ពិធីសារនេះ ជាកម្មវត្ថុនៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមដោយភាគីចុះកិច្ចសន្យា

-លិខិតុបករណ៍នៃការធ្វើសច្ចាប័ន ឬការចូលត្រូវតម្កល់នៅលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកផ្សព្វផ្សាយយ៉ាងរហ័សទៅភាគីចុះកិច្ចសន្យា

-ពិធីសារចូលជាធរមាននៅពេលលិខិតុបករណ៍នៃការធ្វើសច្ចាប័ន ឬការចូលពីគ្រប់ភាគីបានតម្កល់ទុកនៅលេខាធិ-ការដ្ឋានអាស៊ាន

- វិសោធនកម្មនៃពិធីសារ និងឧបសម្ព័ន្ធរបស់វាអាចប្រព្រឹត្តទៅបាន តាមការព្រមព្រៀងពីគ្រប់ភាគីទាំងអស់ ។

អាស្រ័យដូចបានទូលថ្វាយ និងជម្រាបជូនខាងលើនេះ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារអាស៊ាន ស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោកនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

## ពិធីសារទី ៣
## ប្រភេទ និងបរិមាណយានយន្តផ្លូវគោក

❖❖❖❖❖⁜❖❖❖❖❖

រដ្ឋាភិបាល នៃប្រទេស ប្រ៊ុយណេ ដារូសាឡាម, ព្រះរាជាណាចក្រកម្ពុជា, សាធារណរដ្ឋឥណ្ឌូណេស៊ី, សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ, ប្រទេសម៉ាឡេស៊ី, សាធារណរដ្ឋហ្វីលីពីន, សាធារណរដ្ឋសិង្ហបុរី, ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម, គឺជារដ្ឋសមាជិក នៃសមាគមប្រជាជាតិ អាស៊ីភាគអាគ្នេយ៍ (ពីពេលនេះតទៅ ហៅកាត់ថា " ភាគីចុះកិច្ចសន្យា " )

**រំលឹកឡើងវិញ** កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរបសំរួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខា នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៩៨ នៅទីក្រុងហាណូយ ប្រទេសវៀតណាម (ពីពេលនេះតទៅហៅកាត់ថា " កិច្ចព្រមព្រៀង " )

**កត់សំគាល់** ថាមាត្រា ៩ និង ២៥ នៃកិច្ចព្រមព្រៀងនោះ ផ្តល់អោយសំរាប់ការសំរេចនូវការអនុវត្តន៍ពិធីសារដែលនឹងបង្កើតទៅជាផ្នែករួមបញ្ចូលគ្នា ជាមួយកិច្ចព្រមព្រៀង ។

**រំលឹកឡើងវិញបន្ថែម** នូវផែនការសកម្មភាព ទីក្រុងហាណូយ ដែលបានយល់ព្រមដោយបណ្តាប្រមុខរដ្ឋ និងរដ្ឋាភិបាលអាស៊ាន នៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទី ៦ នៅទីក្រុងហាណូយ ប្រទេសវៀតណាម នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលចែងអោយធ្វើការប្រតិបត្តិ កិច្ចព្រមព្រៀងនៅឆ្នាំ ២០០០ ។

**បច្ចុប្បន្នដោយហេតុដូចនោះ បណ្តាភាគីចុះកិច្ចសន្យា បានព្រមព្រៀងគ្នាដូចខាងក្រោម :**

### មាត្រាទី ១
### និយមន័យ

សំរាប់បំរើអោយគោលបំណងនៃពិធីសារនេះ

ក- " ប្រតិបត្តិករ ដឹកជញ្ជូនឆ្លងកាត់ " មានន័យថា បណ្តាម្ចាស់កម្មសិទ្ធរថយន្ត អ្នកបើកបរ និង / ឬ ក៏បណ្តាភ្នាក់ងារទាំងឡាយនៃយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក ដែលជាអ្នកមានការអនុញ្ញាត ឬមានអាជ្ញាប័ណ្ណអនុញ្ញាតថ្នាក់ជាតិ យ៉ាងសមរម្យ ដើម្បីប្រតិបត្តិនូវសេវាដឹកជញ្ជូន និងជាអ្នកដែលបានចុះបញ្ជី ក្នុងការអនុវត្តន៍ ស្របទៅតាមបទប្បញ្ញត្តិ និងនិតិវិធី នៅក្រោមការអនុញ្ញាត ឬអាជ្ញាប័ណ្ណអនុញ្ញាត ដែលបាននិយាយខាងលើ និងដែលបានចុះបញ្ជី យ៉ាងត្រឹមត្រូវថាជា " ប្រតិបត្តិករដឹក

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

ជញ្ជូនឆ្លងកាត់ " ជាមួយនឹង គណៈកម្មការជាតិ សំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ ( គជសដឆ ) របស់ពួកគេទាំងឡាយរៀងៗខ្លួន ។

ខ- " យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក " មានន័យថា ជាប្រភេទនៃយានយន្តលើផ្លូវគោកទាំងឡាយដែលបានបញ្ជាក់ ក្នុងមាត្រាទី ៣ នៅទីនេះសំរាប់ការប្រើប្រាស់ក្នុងការដឹកទំនិញឆ្លងកាត់ដែនដីនៃភាគីចុះកិច្ចសន្យាមួយ ឬច្រើន នៅពេលដែលការធ្វើដំណើរឆ្លងកាត់នោះធ្វើឡើងកាត់តាមដែនដី ឬដែនដីទាំងឡាយដូចខាងលើនេះ ដោយមានជាប់ជាមួយ ឬមិនមានជាប់ជាមួយ នូវបន្ទុកទំនិញ ការស្តុកទំនិញបណ្តោះអាសន្ន នៅកន្លែងទុកដាក់ណាមួយ ការបំបែកទំនិញជាដុំៗដាច់ពីគ្នា ឬក៏ការផ្លាស់ប្តូរប្រភេទ នៃការដឹកជញ្ជូន គឺគ្រាន់តែជាចំណែកមួយ នៃការធ្វើដំណើរមួយចប់ផ្លូវ ដោយចាប់ផ្តើម និងបញ្ចប់ ទៅហួស ឬនៅក្រៅវង្វង់ព្រំដែន នៃភាគីចុះកិច្ចសន្យាមួយ ឬច្រើន ដែលចរាចរឆ្លងកាត់ធ្វើឡើងកាត់តាមដែនដី នៃភាគីនោះ ។

គ- " ការដឹកជញ្ជូនឆ្លងកាត់ " ត្រូវមានអត្ថន័យដូចបានកំណត់អោយវានៅក្នុងកិច្ចព្រមព្រៀង ។

ឃ- " ពិធីសារទី៤ " មានន័យថាពិធីសារទី ៤ ស្តីពី តម្រូវការបច្ចេកទេសយានយន្ត ដោយអនុលោមទៅតាមកិច្ចព្រមព្រៀង ។

## មាត្រាទី ២
## ទំហំនៃការអនុវត្តន៍

១- អនុលោមទៅតាមប្រការ ៩.២ នៃ " កិច្ចព្រមព្រៀង " ភាគីចុះកិច្ចសន្យាទាំងឡាយ តាមរយៈនេះយល់ព្រមធ្វើតាមបញ្ញត្តិទាំងឡាយ នៃពិធីសារនេះ ទៅលើយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោកមួយ ដែលចូលរួមក្នុងការដឹកជញ្ជូនឆ្លងកាត់ ។

២- ពិធីសារនេះត្រូវអនុវត្តទៅលើគ្រប់បណ្តាយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក និងអ្នកប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ដូចដែលបានកំណត់ក្នុងមាត្រា ១ នៃពិធីសារនេះ ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

## មាត្រាទី ៣
## ប្រភេទនានាទាំងឡាយ នៃយានយន្ត

ភាគីចុះកិច្ចសន្យាទាំងឡាយតាមរយៈនេះយល់ព្រមថា អ្នកធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់និមួយៗ មិនត្រូវបានគេអនុញ្ញាត អោយចូលរួមក្នុងការដឹកជញ្ជូនឆ្លងកាត់ ដោយប្រើប្រាស់យានយន្តតាមផ្លូវគោកទាំងឡាយផ្សេងៗទៀត ក្រៅអំពីយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោកដែលបានកំណត់ នៅក្នុងឧបសម្ព័ន្ធ ១ ។

## មាត្រាទី ៤
## បរិមាណ

អនុលោមទៅតាមមាត្រាទី៩.២ នៃកិច្ចព្រមព្រៀង ភាគីចុះកិច្ចសន្យាទាំងឡាយតាមរយៈនេះយល់ព្រមថា បរិមាណនៃយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោកទាំងឡាយ ដែលត្រូវបានគេអនុញ្ញាត ដើម្បីអោយប្រើប្រាស់ក្នុងការដឹកជញ្ជូនឆ្លងកាត់ ត្រូវមានបរិមាណយានយន្ត ហុកសិប (៦០) សំរាប់ភាគីចុះកិច្ចសន្យា និមួយៗ ។ ជាបន្តបន្ទាប់មកទៀត បរិមាណនៃយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក នឹងត្រូវលើកយកមកពិភាក្សាគ្នា ពីមួយពេលទៅមួយពេល រវាងបណ្តាភាគីចុះកិច្ចសន្យាទាំងឡាយ ។

## មាត្រាទី ៥
## ភាតព្វកិច្ច

១- យោងតាមមាត្រាទី ២៤ នៃកិច្ចព្រមព្រៀង ភាគីចុះកិច្ចសន្យាទាំងឡាយតាមរយៈនេះយល់ព្រមអនុញ្ញាតអោយមានការចេញ-ចូល និងចល័តដោយពុំមានការរារាំង នូវយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក នៅលើផ្លូវដឹកជញ្ជូនឆ្លងកាត់ដែលបានកំណត់ ។

២- ភាគីចុះកិច្ចសន្យាទាំងឡាយត្រូវប្រកាន់យកនូវវិធានការសមស្របនានា ដើម្បីធានាថាបណ្តាយានយន្តដឹកជញ្ជូនឆ្លងកាត់ទាំងឡាយរបស់ពួកគេរៀងៗខ្លួន អនុវត្តតាមបទប្បញ្ញត្តិទាំងឡាយ នៃការដឹកជញ្ជូនទៅតាមផ្លូវគោក នៃភាគីចុះកិច្ចសន្យា ដែលចរាចរឆ្លងកាត់ធ្វើឡើងកាត់តាមទឹកដី នៃភាគីនោះ ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

## មាត្រាទី ៦
## តម្រូវការខាងបច្ចេកទេសចាំបាច់ទាំងឡាយ

យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក ដែលត្រូវអនុវត្តទៅតាមពិធីសារនេះ មិនត្រូវបានគេអនុញ្ញាតអោយចូលរួមក្នុងការដឹកជញ្ជូនឆ្លងកាត់ លើកលែងតែវាបានបំពេញទៅតាមតម្រូវការខាងបច្ចេកទេសចាំបាច់ទាំងឡាយ ដូចដែលគេបានបញ្ជាក់ក្នុងពិធីសារទី ៤ ។

## មាត្រាទី ៧
## ការរៀបចំស្ថាប័ន

១- កិច្ចប្រជុំមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ានត្រូវតែជាអ្នកទទួលខុសត្រូវ សំរាប់ការត្រួតពិនិត្យ តាមដាន ការពិនិត្យមើលឡើងវិញ ការសំរបសំរួល និងការត្រួតត្រាមើល នូវគ្រប់ទិដ្ឋភាពទាំងអស់ដែលជាប់ពាក់ព័ន្ធទៅនឹងការប្រតិបត្តិ ដោយ មានប្រសិទ្ធភាព នៃពិធីសារនេះ ។

២- កិច្ចប្រជុំមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ានត្រូវដាក់ស្នើ តាមរយៈលេខាធិការដ្ឋានអាស៊ាន នូវរបាយការណ៍ជាទៀងទាត់ ស្តីពីភាពជឿនលឿន នៃការប្រតិបត្តិ នូវពិធីសារទាំងនេះ ទៅក្រុមប្រឹក្សាគិបាលសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ ដែល បានបង្កើតឡើង ដោយអនុលោមទៅតាមមាត្រាទី ២៩.២ នៃកិច្ចព្រមព្រៀង សំរាប់សកម្មភាពនានាបន្ថែមទៀត ។

៣- លេខាធិការដ្ឋានអាស៊ាន ត្រូវផ្តល់នូវការទ្រទ្រង់ និងជំនួយបច្ចេកទេស ដល់កិច្ចប្រជុំមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់របស់អាស៊ាន ក្នុងមុខការ និងការទទួលខុសត្រូវរបស់ខ្លួន ស្របទៅតាមពិធីសារនេះ ។

## មាត្រាទី ៨
## អវសានបញ្ញត្តិ

១- ពិធីសារនេះនឹងត្រូវបានគេតំកល់ទុកនៅ អគ្គលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកផ្សព្វផ្សាយជាបន្ទាន់ នូវច្បាប់ចំលង ដែលជាការបញ្ជាក់មួយ ទៅគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ ។

២- ពិធីសារនេះនិងឧបសម្ព័ន្ធទាំងឡាយរបស់វា ត្រូវបង្កើតឡើងបានជាផ្នែករួមបញ្ចូលគ្នាជាមួយកិច្ចព្រមព្រៀង ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

៣- ពិធីសារនេះគឺជាកម្មវត្ថុ ក្នុងការធ្វើសច្ចាប័ន ឬ ការយល់ព្រមដោយភាគីចុះកិច្ចសន្យា ។ លិខិតតុបករណ៍ នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមចូល ត្រូវតំកល់ទុកនៅជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្តល់ពត៌មានយ៉ាងរហ័ស ទៅភាគី ចុះកិច្ចសន្យានិមួយៗ នូវការតំកល់ទុកដូចនេះ ។

៤- ពិធីសារនេះ នឹងត្រូវចូលជាធរមាន ក្នុងពេលដែលការតំកល់ទុកនូវលិខិតតុបករណ៍ នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រម ពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ នៅជាមួយនឹងអគ្គលេខាធិការអាស៊ាន ។

៥- ការធ្វើវិសោធនកម្មណាមួយ ទៅលើប្រការទាំងឡាយ ដែលមានចែងនៅក្នុងពិធីសារនេះ និងឧបសម្ព័ន្ធទាំងឡាយរបស់វា នឹងប្រព្រឹត្តទៅបានតាមរយៈការព្រមព្រៀងគ្នា នៃភាគីជាប់កិច្ចសន្យាទាំងអស់ ។

ដើម្បីទុកជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធប្រទានយ៉ាងត្រឹមត្រូវ ដើម្បីចុះហត្ថលេខាពីរដ្ឋាភិបាលរបស់ពួកគេទាំងឡាយរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារទី ៣ ស្តីពីប្រភេទ និងបរិមាណយានយន្តផ្លូវគោក ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរួលទំនិញឆ្លងកាត់ ។

ធ្វើនៅ. ទីក្រុងហាណូយ. វៀតណាម នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ ជាច្បាប់ទោលតែមួយគត់ សរសេរជាភាសាអង់គ្លេស ។

..............................................................

PENIN DATO HAJI ZAKARIA SULAIMAN

រដ្ឋមន្ត្រីគមនាគមន៍

ប្រ៊ុយណេដារូសាឡាម

..............................................................

KHY TAINGLIM

រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន

ព្រះរាជាណាចក្រកម្ពុជា

..............................................................

AGUM GUMELAR

អគ្គលេខាធិការ ក្រសួងគមនាគមន៍

សាធារណរដ្ឋឥណ្ឌូណេស៊ី

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

.........................................................
PHAO BOUNNAPHAL
រដ្ឋមន្ត្រីគមនាគមន៍, ដឹកជញ្ជូន, ប្រៃសណីយ៍ និងសំណង់
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

.........................................................
DATO' SERI DR. LING LIONG SIK
រដ្ឋមន្ត្រីដឹកជញ្ជូន
ម៉ាឡេស៊ី

.........................................................
MAJ GEN HLA MYINT SWE
រដ្ឋមន្ត្រីដឹកជញ្ជូន
សហភាពមីយ៉ាន់ម៉ា

.........................................................
VICENTE C. RIVERA. JR.
រដ្ឋលេខាធិការ ដឹកជញ្ជូន និងគមនាគមន៍
សាធារណរដ្ឋហ្វីលីពីន

.........................................................
YEO CHEOW TONG
រដ្ឋមន្ត្រីគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន
សាធារណរដ្ឋសិង្ហបុរី

.........................................................
SUTHEP THAUGSUBAN
រដ្ឋមន្ត្រីដឹកជញ្ជូន និងគមនាគមន៍
ព្រះរាជាណាចក្រថៃឡង់ដ៍

.........................................................
LE NGOC HOAN
រដ្ឋមន្ត្រីដឹកជញ្ជូន
សាធារណរដ្ឋសង្គមនិយមវៀតណាម

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

# ឧបសម្ព័ន្ធទី ១

## [ប្រការទី ៣(២)]

**ប្រភេទនានាទាំងឡាយ នៃយានយន្ត**

យានយន្តដឹកជញ្ជូនឆ្លងកាត់លើផ្លូវគោក ដែលត្រូវបានគេអនុញ្ញាត តាមពិធីសារនេះ ត្រូវមានប្រភេទទាំងឡាយដូចខាងក្រោម :

១- " Rigid Motor Vehicle " " យានយន្តជាប់រឹងគ្មានតំណ " មានន័យថា ជាយានយន្តមួយផ្សេងអំពីយានយន្ត ជាក្បាលសណ្តោង ឬជាយានយន្តមានតំណចល័ត ជាពិសេសគឺជាយានយន្ត ពាណិជ្ជកម្មមួយ ដែលទទួលយកបន្ទុកទំនិញ នៅពីលើភ្លៅរបស់វា ។

២- " Articulated Vehicle " mean a prime mover drawing a semi-trailer

៣- "រ៉ឺម៉កពាក់កណ្តាលសណ្តោង " មានន័យថា ជាយានយន្តមួយដែលអូសទាញ ឬសណ្តោងដោយយានយន្ត (រថយន្ត) មួយនៅក្នុងស្ថានភាពមួយ ដែលផ្នែកនៃរ៉ឺម៉កត្រូវបានដាក់ភ្ជាប់ពីលើយានយន្តនោះ ហើយដែលផ្នែកដ៏ធំនៃទំងន់រ៉ឺម៉ក និងបន្ទុករបស់វា បត់បែនបានទៅតាមយានយន្ត ។

សំរាប់ជាគោលបំណង នៃពិធីសារនេះ យានយន្តជាប់រឹងគ្មានតំណ " Rigid Motor Vehicle " និងយានយន្តមានតំណ " Articulated Vehicle " ត្រូវបានគេចាត់ថ្នាក់ដូចខាងក្រោម :

| | |
|---|---|
| - រថយន្តទ្រុងដែលមានក្លឹតសៀល ឬ " ក្លឹតត្រា " | Boxed sealed |
| - យានយន្ត បង្កកដែលមាន ក្លឹតសៀល ឬ " ក្លឹតត្រា " | Refrigerated sealed |
| - យានយន្តស៊ីទែន ដែលមានក្លឹតសៀល ឬ " ក្លឹតត្រា " | Tanker sealed |
| - យានយន្តដឹកកុងតែន័រ ដែលមានក្លឹតសៀល ឬ " ក្លឹតត្រា " | Container sealed |

ដែលមាន "ក្លឹតសៀល " ឬ " ក្លឹតត្រា " ត្រូវបានគេកំណត់ជាយានយន្តមួយដែលមានធុង ឬទ្រុងត្រូវបានគេសាងសង់ ឬបំពាក់ឡើងក្នុងសណ្ឋានដូចនេះថា :

ក- សៀល ឬត្រាក្លឹតរបស់គយអាចអោយគេបិទភ្ជាប់ទៅនឹងយានយន្តនោះ បានដោយស្រួល និងមានប្រសិទ្ធភាព ។

ខ- ទំនិញពុំអាចអោយគេលើកផ្ទេរប្តូរ ឬ ប្រើប្រាស់ជាលើកទី ១ ដោយផ្នែកដែលក្លឹតសៀល ឬ ត្រា នៃយានយន្ត ពុំមានមើលឃើញការចេញស្នាម នៃការបើកដោយខុសច្បាប់ ឬ ក៏ពុំមានការបែកបាក់ នូវស៊ីលរបស់គយ ។

គ- វាពុំមានកន្លែងលាក់បាំងលើយានយន្ត ដែលគេអាចលាក់ទំនិញបាន ។

ឃ- គ្រប់កន្លែងទាំងអស់លើយានយន្ត ដែលអាចផ្ទុកទំនិញបាន ត្រូវអាចអោយគេចូលទៅដល់បាន ដោយស្រួល សំរាប់ការត្រួតពិនិត្យគយ ។